**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ..........៥៩...ជខ.សណណ........

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចែកចាយឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ ពីរប្រភេទ សម្រាប់សាធារណជន

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា ដើម្បីបន្តចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានទាន់ពេលវេលា ក្រសួងបើកទូលាយចែកចាយឧបករណ៍តេស្តរហ័សជូនក្រសួង-ស្ថាប័ន ក្រុមហ៊ុន សហគ្រាស រោងចក្រ មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង ភ្នាក់ងារចែកចាយ និងសាធារណជន នូវឧបករណ៍តេស្តរហ័សពីរប្រភេទដូចខាងក្រោម៖

១. ឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ SD Biosensor (Standard Q) ផលិតនៅប្រទេសកូរ៉េ ១ប្រអប់មាន២៥ឧបករណ៍តេស្ត ហើយ១ឧបករណ៍តេស្ត តម្លៃ ៣,៧ ដុល្លារអាម៉េរិក (ត្បារយកសំណាកពីក្នុងរន្ធច្រមុះ)

២. ឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ Healgen Antigen Rapid Test ផលិតនៅប្រទេសចិន ១ប្រអប់មាន២០ឧបករណ៍តេស្ត ហើយ១ឧបករណ៍តេស្ត តម្លៃ ២ ដុល្លារអាម៉េរិក (ត្បារយកសំណាកពីក្នុងរន្ធច្រមុះ)។

ដូចនេះ ក្រសួង-ស្ថាប័ន ក្រុមហ៊ុន សហគ្រាស រោងចក្រ មន្ទីរពេទ្យឯកជន គ្លីនិក ឱសថស្ថាន ឱសថស្ថានរង ភ្នាក់ងារចែកចាយ និងសាធារណជនអាចបញ្ជាទិញឧបករណ៍តេស្តចាប់ពី ១ប្រអប់ឡើងទៅ ដោយចូលទៅកាន់ប្រព័ន្ធស្វ័យប្រវត្តិកម្មដែលមានតំណភ្ជាប់ **mptc.gov.kh/rt** ឬ **អញ្ជើញមកទិញដោយផ្ទាល់**នៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលមានអាសយដ្ឋាន អគារលេខ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ចំពោះការទូទាត់អាចផ្ទេរមកគណនីធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ (ABA Bank) របស់ក្រសួងដែលមានឈ្មោះគណនី MPTC និងលេខគណនី 567 789 123។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទូរសព្ទលេខ ១២៣ / ០៦៧ ៨១៨ ៧៨២ / ០១៧ ៨៤៨ ១០៨ / ០៧៧ ៨៦៧ ៩៥៧ ជារៀងរាល់ថ្ងៃ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១៥កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១


អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.mptc.gov.kh
ទូរសព្ទ : (៨៥៥) ២៣ ៧២៤ ៨១០
ទូរសារ : (៨៥៥) ២៣ ៧២៤ ០៦៩
អ៊ីមែល : info@mptc.gov.kh

# ឧបករណ៍តេស្តរហ័សអង់ទីហ្សែនកូវីដ-១៩
## ទទួលស្គាល់ និងអនុញ្ញាតឱ្យប្រើប្រាស់ដោយក្រសួងសុខាភិបាល
## ចែកចាយដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## SD BIOSENSOR




**STANDARD Q COVID-19 Ag Test**
**ក្រុមហ៊ុន SD BIOSENSOR**
**ផលិតនៅប្រទេសកូរ៉េ**

ចំនួនតេស្តក្នុង **1** ប្រអប់ = **25** ឧបករណ៍តេស្ត

តម្លៃ : **3,7$** ក្នុងមួយឧបករណ៍តេស្ត

ការយកសំណាក : ត្បារយកសំណាកពីក្នុងរន្ធច្រមុះ

**ក្នុងមួយប្រអប់រួមមាន :**
បន្ទះតេស្តរហ័ស ចំនួន២៥, តម្បារ ចំនួន២៥, ទឹក និងទីបសូលុយស្យុង Buffer និងគម្រប ចំនួន២៥ឈុត, បន្ទះទម្រទីប ចំនួន១ឈុត

## HEALGEN



**Healgen Coronavirus Ag Rapid Test**
**ក្រុមហ៊ុន Healgen Scientific LLC**
**ផលិតនៅប្រទេសចិន**

ចំនួនតេស្តក្នុង **1** ប្រអប់ = **20** ឧបករណ៍តេស្ត

តម្លៃ : **2$** ក្នុងមួយឧបករណ៍តេស្ត

ការយកសំណាក : ត្បារយកសំណាកពីក្នុងរន្ធច្រមុះ

**ក្នុងមួយប្រអប់រួមមាន :**
បន្ទះតេស្តរហ័ស ចំនួន២០, តម្បារ ចំនួន២០, ទឹកសូលុយស្យុង Buffer ចំនួន២ដប, ទីបដាក់ទឹកសូលុយស្យុង និងគម្រប ចំនួន២០ឈុត, បន្ទះទម្រទីប ចំនួន១ឈុត

### ចំណាំ

- សូមរក្សាទុកក្នុងសីតុណ្ហភាពចន្លោះពី ២ ទៅ ៣០ អង្សាសេ
- ឧបករណ៍តេស្តមួយ ប្រើបានតែ ១ដងគត់
- កាលបរិច្ឆេទផុតសុពលភាពនៃឧបករណ៍តេស្ត ២៤ខែ ក្រោយថ្ងៃផលិត

ស្កេនដើម្បីទស្សនាវីដេអូ
**វិធីប្រើឧបករណ៍តេស្តរហ័ស**
**អង់ទីហ្សែនកូវីដ-១៩**
**ឬ ចូល** https://fb.watch/74s33nCA8y/

យោងសេចក្តីជូនដំណឹង លេខ ៥៩ បទ.សជណ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១